***សេចក្តីប្រកាសព័ត៌មាន***

**ភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៦** - របាយការណ៍ថ្មីដែលចេញផ្សព្វផ្សាយថ្ងៃនេះ បានប្រកាសថា ប្រទេសកម្ពុជាមានការរីកចំរើនលើសពីការរំពឹងទុក ក្នុងការកាត់បន្ថយភាពក្រីក្រ ក្នុងទសវត្សកន្លងទៅ ប៉ុន្តែប្រទេសកម្ពុជាត្រូវការការផ្លាស់ប្តូរស្ថាប័ន និងគោលនយោបាយដែលថ្មី និងមានភាពស្មុគស្មាញជាងមុន ព្រមទាំងការពង្រឹងភាពជាដៃគូ ប្រសិនបើប្រទេសនេះចង់សំរេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់ខ្លួន ក្នុងការកាត់បន្ថយភាពក្រីក្រឱ្យបានពាក់កណ្តាលនៅ រវាងឆ្នាំ ២០១៥ និងផ្តល់ជូនប្រជាជនកម្ពុជារាប់លាននាក់នូវជីវភាពល្អប្រសើរជាងមុន។

**ការវាយតំលៃភាពក្រីក្រនៅប្រទេសកម្ពុជាឆ្នាំ ២០០៦** បានចាប់ផ្តើមប្រព្រឹត្តទៅនៅថ្ងៃនេះ នៅក្នុងសិក្ខាសាលា "**ប្រទេសកម្ពុជាៈ តើភាពក្រីក្រអាចកាត់បន្ថយអស់ពាក់កណ្តាលបានទេនាឆ្នាំ ២០១៥?**" ហើយដែលសិក្ខាសាលានេះបានបើក ដោយ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** និងចូលរួមដោយសមាជិករដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយចំនួន ជាង ២០០ នាក់។ ជាលើកទីមួយហើយដែលការវាយតំលៃភាពក្រីក្រ បានបង្ហាញពីការប៉ាន់ស្មានដែលអាចប្រៀបធៀបបាន ស្តីពីការប្រើប្រាស់របស់គ្រួសារ និងភាពក្រីក្រនៅឆ្នាំខុសៗគ្នានៅប្រទេសកម្ពុជា ព្រមទាំងកំណត់អត្តសញ្ញាណ ជោគជ័យ មេរៀន និងគំនិតថ្មីគន្លឹះ ដែលលេចចេញពីប្រទេសកម្ពុជា ក៏ដូចជា បញ្ហាប្រឈមដែលនៅសេសសល់ក្នុងការកាត់បន្ថយភាពក្រីក្រក្នុងប្រទេស។ សន្និសិទនេះត្រូវបានរៀបចំឡើងដោយធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្រសួងអភិវឌ្ឍន៍អន្តរជាតិរបស់ចក្រភពអង់គ្លេស (DFID) និងអង្គការសហប្រជាជាតិ (UN) និងរួមសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ។

ការវាយតំលៃភាពក្រីក្រនឹងក្លាយជាទិន្នផលដ៏សំខាន់សំរាប់សន្និសិទអន្តរជាតិ **ទ្វីបអាស៊ីឆ្នាំ ២០១៥ៈ ការលើកកំពស់កំណើនសេដ្ឋកិច្ច ការបញ្ចប់ភាពក្រីក្រ** ដែលនឹងប្រព្រឹត្តនៅថ្ងៃ ៦-៧ ខែមិនា នៅទីក្រុងឡុងដ៍ ហើយដែលឧបត្ថម្ភដោយក្រសួងអភិវឌ្ឍន៍អន្តរជាតិរបស់ចក្រភពអង់គ្លេស (DFID) ដោយសហការជាមួយនឹងធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដោយមានការសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ។

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបើកកម្មវិធីផ្សព្វផ្សាយការវាយតំលៃភាពក្រីក្រ ដោយស្វាគមន៍តួលេខពីភាពក្រីក្រថ្មីៗ និងរំលឹកដល់អ្នកចូលរួមថា សន្ទុះនៃការរីកចំរើន ដែលនាំអោយមានការកាត់បន្ថយភាពក្រីក្រកាលពីទសវត្សកន្លងទៅ គឺពឹងផ្អែកជាចំបងទៅលើ ការនាំចេញក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលបានបង្កើតការងារជាច្រើន នៅតំបន់ទីក្រុង ប៉ុន្តែមានឥទ្ធិពលតិចតួច នៅតំបន់ជនបទ ដែលប្រជាជនក្រីក្រ៩១% រស់នៅ។ សម្តេចមានប្រសាសន៍ថា "*កសិដ្ឋានខ្នាតតូច ត្រូវបានមើលឃើញថា មានផលិតភាពខ្ពស់ និងបង្កើនការងារ ច្រើនជាង*

*កសិដ្ឋានខ្នាតធំៈ ដូចនេះ រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា គួរផ្តោតអារម្មណ៍ទៅលើការបង្កើតគោលនយោបាយ ដើម្បីជួយកសិករដែលប្រកបការងារកសិកម្មលើកសិដ្ឋានតូចៗ អោយបង្កើនផលិតភាព និងទីផ្សារសំរាប់កសិផល របស់ពួកគាត់។ សម្បទានដីសង្គមកិច្ច ក៏ជាកត្តាមួយសំខាន់ណាស់ដែរ ដើម្បីកាត់បន្ថយភាពក្រីក្រ។ វាមានសារ សំខាន់ណាស់ដើម្បីកំណត់សម្បទានសេដ្ឋកិច្ចដែលមិនដំណើរការ និងកែប្រែដីដែលគ្មានផលិតភាព អោយទៅជាដីដែល មានផលិតភាព តាមរយៈការអនុវត្តអនុក្រិតស្តីអំពីដីសម្បទានសង្គមកិច្ច ។*

*ឯកសារវាយតំលៃពីភាពក្រីក្របានលើកទឹកចិត្តដល់ការខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា យើងបានជ្រើសរើសផ្លូវដ៏ត្រឹមត្រូវក្នុងការអភិវឌ្ឍន៍ និងកាត់បន្ថយភាពក្រីក្រ ។ ទោះជាយ៉ាងណាក៏ដោយ យើងមាន លទ្ធភាពកែលំអលើសមិទ្ធិផលរបស់យើងកន្លងមក ដោយខិតខំទ្វេដងថែមទៀត។ ខ្ញុំជឿជាក់ថា ឯកសារវាយតំលៃ ភាពក្រីក្រនេះ ផ្តល់តំលៃបន្ថែមទៀត ចំពោះកិច្ចខិតខំប្រឹងប្រែង របស់យើងដើម្បីធានានូវសុក្រឹតភាព និងសមភាព អោយកាន់តែប្រសើរ និងជួយតំរង់ទិសដៅសំរាប់គោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងការពន្លឿនការកាត់បន្ថយ ភាពក្រីក្រ។"*

**ឯកឧត្តមទេសរដ្ឋមន្ត្រី គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានប្រសាសន៍ថា *"រាជរដ្ឋាភិបាលកម្ពុជា ប្រកាន់ឆន្ទៈមោះមុត ជាប្រចាំក្នុងការកាត់បន្ថយភាពក្រីក្រ។ ការកាត់បន្ថយភាពក្រីក្រ ជាស្នូលនៃគ្រប់គោល នយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ទាំងអស់របស់រាជរដ្ឋាភិបាល ។ យុទ្ធសាស្ត្រចតុកោណ បានកំណត់គោលដៅ ពិសេសលើការជំរុញកំណើនសេដ្ឋកិច្ច ការបង្កើតការងារជូនប្រជាជនកម្ពុជាឱ្យបានពេញលេញ ការបែងចែកផលនៃ កំណើនដោយសមធម៌ ដើម្បីធានាយុត្តិធម៌សង្គម ព្រមទាំងការពង្រឹងប្រសិទ្ធិភាពក្នុងវិស័យសាធារណៈ តាមរយៈការ អនុវត្តកម្មវិធីកំណែទំរង់ផ្សេងៗដែលមានលក្ខណៈស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ ។* **ឯកឧត្តមបានបន្តថា** *"សន្និសិទរួម គ្នារបស់យើងនៅពេលនេះ នឹងបន្តពិភាក្សាលើរបកគំហើញនៃរបាយការណ៍ ហើយនឹងព្យាយាមស្វែងរកវិធីដំណើរការ ដោយច្នៃប្រឌិតឆ្ពោះទៅមុខទៀត ជាពិសេសការកំណត់នូវរបៀបវារៈរហូតដល់ឆ្នាំ ២០១៥ ក្នុងការពង្រឹងភាពជាដៃគូ ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរកម្ពុជា។"*

## ភាពជឿនលឿនរបស់ប្រទេសកម្ពុជា

ការវាយតំលៃភាពក្រីក្រថ្មី - ផ្អែកលើការអង្កេតសង្គមកិច្ច-សេដ្ឋកិច្ចថ្នាក់ជាតិឆ្នាំ ២០០៤ និងការសិក្សា ស្រាវជ្រាវជាលក្ខណៈពិសេសមួយចំនួន - រកឃើញថា ក្នុងទសវត្សកន្លងទៅ ប្រទេសកម្ពុជាបានធ្វើឱ្យមានវឌ្ឍនភាព យ៉ាងធំធេងក្នុងការកាត់បន្ថយភាពក្រីក្រ។ ក្នុងរយៈពេល១០ឆ្នាំកន្លងទៅនេះ តាមការប៉ាន់ស្មាន បរិមាណប្រជាជន ដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រថ្នាក់ជាតិបានធ្លាក់ចុះពី ៤៧ ភាគរយ មកនៅត្រឹម ៣៥ ភាគរយ នៅថ្ងៃនេះ។ ក្នុង

ទសវត្សកន្លងទៅប្រទេសកម្ពុជាបានពង្រឹងសន្តិភាព និងសំរេចបានកំណើនសេដ្ឋកិច្ចក្នុងកំរិតជាង ៧ ភាគរយក្នុងមួយឆ្នាំ។ ការកែលំអសូចនាករក្រៅពីប្រាក់ចំណូល - ដែលរួមមាន កម្មសិទ្ធិលើឧបករណ៍ប្រើប្រាស់បានយូរ គុណភាពផ្ទះសំបែង និងការចូលរៀនក្នុងសាលា ជាឧទាហរណ៍ - បញ្ជាក់ពីរូបភាពនៃការកើនឡើងចំពោះកំរិតជីវភាពរបស់ប្រជាជនភាគច្រើន។

**លោកស្រី នីសា អាក្រាវ៉ាល នាយិកាគ្រប់គ្រងនៃធនាគារពិភពលោកប្រចាំនៅប្រទេសកម្ពុជា** បានមានប្រសាសន៍ថា *"ប្រទេសកម្ពុជាបានធ្វើវឌ្ឍនភាពយ៉ាងធំធេងឆ្ពោះទៅកាន់គោលដៅអភិវឌ្ឍន៍សហសវត្សនៅកម្ពុជា (CMDGs) ដែលនឹងនាំឱ្យរាជរដ្ឋាភិបាលអាចកាត់បន្ថយបរិមាណប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្របានចំនួនពាក់កណ្តាល នៅរវាងឆ្នាំ ១៩៩៣ និងឆ្នាំ ២០១៥។ ដោយចាប់ផ្តើមពីមូលដ្ឋាននៃប្រាក់ចំណូលទាបខ្លាំង និងភាពក្រីក្រកំរិតខ្ពស់ នៅដើមទសវត្សឆ្នាំ ៩០ ការទទួលបានសន្តិភាព និងសេរីភាវូបនីយកម្មសេដ្ឋកិច្ចបានធ្វើឱ្យមានកំណើន និងការកាត់បន្ថយភាពក្រីក្រយ៉ាងរហ័ស។ នៅពេលដែលប្រទេសកម្ពុជាបោះជំហានទៅមុខ បញ្ហាប្រឈមថ្មីៗ និងការរំពឹងទុក វានឹងទាមទារឱ្យមានកំណែទំរង់កាន់តែស៊ីជំរៅ និងឆ្លុះបញ្ចាំងពីបញ្ហាប្រឈម និងការរំពឹងទុកថ្មីៗ របស់ប្រទេស"*។

ប៉ុន្តែ **ការវាយតំលៃភាពក្រីក្រ** កត់សំគាល់ថា ក្នុងទសវត្សកន្លងទៅ នៅពេលដែលប្រជាជនគ្រប់ស្រទាប់សង្គមបានទទួលផលចំណេញ ការកែលំអកំរិតជីវភាពរស់នៅត្រូវបានទទួលស្គាល់ជាទូទៅយ៉ាងខ្លាំងក្លាជាងគេតែចំពោះក្រុម និងតំបន់មួយចំនួនប៉ុណ្ណោះ ហើយវិសមភាពបានកើនឡើងយ៉ាងសំបើម។ ទោះបីភាពក្រីក្រនៅជនបទនានាបានធ្លាក់ចុះប្រមាណ ២០ ភាគរយ ក្នុងទសវត្សកន្លងទៅចន្លោះនៃការអង្កេតពី ភាពក្រីក្រនោះឃើញថា នៅក្រុងភ្នំពេញបានធ្លាក់ចុះប្រហែល ៦០ ភាគរយ (និង ៤៤ ភាគរយនៅតំបន់ទីក្រុងផ្សេងទៀត)។ នៅឆ្នាំ ២០០៤ ប្រជាជនក្រីក្រនៅកម្ពុជាមានចំនួន ៩០ ភាគរយ រស់នៅក្នុងតំបន់ជនបទ។ អត្រាភាពក្រីក្រមានកំរិតខ្ពស់ជាងគេបំផុតនៅក្នុងតំបន់ជនបទដាច់ស្រយាលដែលមានការទទួលបានផ្លូវថ្នល់ ទីផ្សារ និងសេវាមូលដ្ឋាននៅមានកំរិត។ អាស្រ័យហេតុនេះ ការលើកកំពស់ការអភិវឌ្ឍន៍នៅជនបទ និងការកែលំអ ជីវិតរបស់ជនក្រីក្រនៅជនបទគឺជាអាទិភាពខ្ពស់ - ដូចផែនការអភិវឌ្ឍន៍ជាយុទ្ធសាស្ត្រថ្នាក់ជាតិ (NSDP) ថ្មី សំរាប់រយៈពេល ៥ ឆ្នាំ ២០០៦-២០១០ របស់រដ្ឋាភិបាលបានទទួលស្គាល់។

វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានចូលរួមយ៉ាងសកម្មក្នុងការវាយតំលៃភាពក្រីក្រដោយមានការចូលរួមសិក្សាស្រាវជ្រាវដល់មូលដ្ឋាន ដែលរួមមាន **ការសិក្សាស្រាវជ្រាវស្តីពីការចេញពីភាពក្រីក្រ** និង**ការវាយតំលៃភាពក្រីក្រតាមការចូលរួម**។ លោក ឡារី ស្រ្តេង (Larry Strange) ប្រធាន

CDRI មានប្រសាសន៍ថា *"ការវាយតំលៃភាពក្រីក្រផ្តល់នូវហេតុផលដែលបង្ខំឱ្យបង្កើនការយកចិត្តទុកដាក់លើការអភិវឌ្ឍន៍ វិស័យកសិកម្មជាចលករគន្លឹះនៃកំណើនសេដ្ឋកិច្ច។ កម្លាំងនៃការភ្ជាប់ប្រកបដោយសក្តានុពលរវាងកំណើនក្នុងវិស័យកសិកម្ម និងការកាត់បន្ថយភាពក្រីក្រនឹងអាស្រ័យលើកិរិតដែលរដ្ឋាភិបាល ម្ចាស់ជំនួយ សង្គមស៊ីវិល និងអ្នកចូលរួម គន្លឹះផ្សេងទៀត អាចសហការគ្នាសំរាប់គោលដៅនៃការគាំទ្រល្អប្រសើរជាងមុនដល់កសិករតូចតាចចំពោះការធានា ការទទួលបាននូវកម្មសិទ្ធិកាន់កាប់ដី និងធនធានធម្មជាតិ ការគ្រប់គ្រងទឹកប្រកបដោយប្រសិទ្ធិភាពការដកចេញ ឧបសគ្គចំពោះប្រសិទ្ធិភាពនៃការរកទីផ្សារ លទ្ធភាពឥណទាន និងការពង្រីកសេវាសំរាប់កសិផលចំរុះ និងផលិតផល នៃការចិញ្ចឹមសត្វ។ ដើម្បីធ្វើសុក្រិតកម្មលើសមត្ថភាពនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជំហានទាំងឡាយ បែបនេះ ត្រូវធ្វើឡើងទន្ទឹមនឹងការបន្តការកែលំអអភិបាលកិច្ច ក៏ដូចជាវិស័យសុខភាព និងអប់រំ ដើម្បីធានាថា ទាំង បុរស និងស្ត្រីទទួលបាននូវផលចំណេញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍សង្គមស្មើៗគ្នា"*។

នៅក្នុងសន្និសិទថ្ងៃនេះ អ្នកចូលរួមបានពិភាក្សាពីការរីកចំរើនរបស់ប្រទេសកម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រ និងបញ្ហាដែលប្រទេសកម្ពុជាត្រូវប្រឈមនាពេលអនាគត ដែលរួមបញ្ចូលទាំងបញ្ហានានាដូចជា សន្តិភាព និង ស្ថេរភាព កំណើនសេដ្ឋកិច្ច និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច សមាហរណកម្មក្នុងតំបន់ និងក្នុងពិភពលោក ការកែលំអសេវាអប់រំ និងសុខាភិបាល។ ខ្លឹមសារបន្ថែមនៃកិច្ចពិភាក្សារួមមានការគ្រប់គ្រងកសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ ការកែលំអភាពប្រកួតប្រជែងរបស់ប្រទេសកម្ពុជា ព្រមទាំងវិធីសាស្ត្រនៃការកសាងរដ្ឋមួយដែលមានប្រសិទ្ធិភាពឆ្លើយតបតាមសំណូមពរ និងទទួលខុសត្រូវរបស់រដ្ឋ។ សន្និសិទនេះក៏នឹងពិភាក្សាផងដែរនូវវិធីសាស្ត្រនៃការពង្រឹងភាពជាដៃគូ គន្លឹះសំរាប់ការកាត់បន្ថយភាពក្រីក្រ។

**លោក សុក ហាច នាយកវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (EIC) មានប្រសាសន៍ថា** *"កម្ពុជាអាចទទួលបាននូវកំណើនខ្ពស់ជាងនេះ គឺប្រមាណពី ៨ - ៩ ភាគរយ ក្នុងមួយឆ្នាំ ដែលក្នុងនោះទទួលបានពី ៥ - ៦ ភាគរយ និងអាចទៅដល់គោលដៅ អភិវឌ្ឍន៍សហសវត្សរ៍សំរាប់ការកាត់បន្ថយភាពក្រីក្រ ក្នុងរយៈពេល១០ ឆ្នាំ ខាងមុខ ប្រសិនបើមានកំណែទំរង់ដ៏ប្រាកដប្រជាមួយ (ដីធ្លី សេវាសង្គមស៊ីវិល និងប្រព័ន្ធយុត្តិធម៌) សំរាប់កែលំអការប្រកួតប្រជែងលើសេដ្ឋកិច្ចកម្ពុជាអាច នឹងត្រូវបានពន្លឿនបាន"*។

យោងតាមប្រសាសន៍លោក ឌូក្លាស ហ្គាន័រ (Douglas Gardner) អ្នកសំរបសំរួលអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា អាទិភាពសំរាប់ជំនួយនាពេលអនាគតដល់ប្រទេសកម្ពុជាត្រូវផ្តោតការយកចិត្តទុកដាក់លើការធ្វើវិនិយោគពិតប្រាកដសំរាប់ជាផលចំណេញដល់ជនក្រីក្រ។ លោកមានប្រសាសន៍ថា *"នៅពេលដែលប្រទេសកម្ពុជានៅតែត្រូវការជំនួយបច្ចេកទេសលើផ្នែកជាក់លាក់សំរាប់ការអភិវឌ្ឍន៍សមត្ថភាព កិច្ចសហប្រតិបត្តិការជំនួយត្រូវការផ្តោត*

*ការយកចិត្តទុកដាក់លើលទ្ធផលជាក់ស្តែង ដែលជនក្រីក្រនៅជនបទមួយភាគធំអាចទទួលផលចំណេញពីតំណាក់កាលថ្មីនៃវឌ្ឍនភាពរបស់ប្រទេសកម្ពុជា"។*

ទោះបីប្រទេសកម្ពុជាមានវឌ្ឍនភាពក្នុងទសវត្សកន្លងទៅ - ជាមួយនឹងអត្រាភាពក្រីក្រដែលបានធ្លាក់ចុះប្រហែល ១ ភាគរយ ជារៀងរាល់ឆ្នាំ តាមការគណនាជាពិន្ទុសំរាប់ទសវត្សកន្លងទៅ - ក៏ដោយ ក៏របាយការណ៍នេះព្រមានថា ភាពក្រីក្រនៅតែរីករាលដាល និងមានពហុវិសាលភាព ដោយមួយភាគបីនៃប្រជាជននៅតែរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ហើយមួយភាគប្រាំកំពុងរស់នៅក្រោមបន្ទាត់ភាពក្រីក្រសំរាប់ស្បៀងអាហារ។ ជនក្រីក្រកំពុងប្រឈមមុខ នឹងបញ្ហាមួយចំនួនដែលស៊ីសង្វាក់យ៉ាងស្អិតរមួត និងជួយជំរុញគ្នាទៅវិញទៅមក ដែលរួមមានកង្វះខាតការធានាពីការទទួលបានកម្មសិទ្ធកាន់កាប់ដី ភាពនៅដាច់ស្រយាលឆ្ងាយពីទីផ្សារ និងសេវាកម្ម កង្វះខាតធនធានសំរាប់ផលិត ក៏រិតអប់រំទាប និងភាពងាយរងគ្រោះចំពោះជំងឺដែលនាំឱ្យមានការចំណាយការព្យាបាលខ្ពស់ ដែលអាចរុញច្រានគ្រួសារ ឱ្យស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រ។

**លោក ធីម ខូនវ៉េ (Tim Corway) អ្នកជំនាញការវិភាគភាពក្រីក្រប្រចាំធនាគារពិភពលោកនៅកម្ពុជាមានប្រសាសនថា** "ដោយប្រទេសកម្ពុជាចូលក្នុងទសវត្សទី ២ នៃតំណាក់កាលក្រោយជំលោះ យើងអាចរំពឹងថាវានឹងមានការថយចុះផលប្រយោជន៍ដែលបានមកពី "ផលចំណេញនៃសន្តិភាព" និងកំណែទំរង់សេរីភាវូបនីយកម្មដែលលើកទឹកចិត្តបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រកន្លងមក - ប្រទេសនេះប្រឈមមុខនឹងបញ្ហាថ្មីៗ ដែលទាមទារឱ្យមានការផ្លាស់ប្តូរស្ថាប័ន និងគោលនយោបាយថ្មី ស្មុគស្មាញ និង ជាសារវ័ន្តជាងមុន"។ ការទាំងអស់នេះរួមមានៈ

- **ការរក្សាអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ និងការកើនឡើងនៃការចំណែកកំណើនសំរាប់ផ្តល់ឱ្យគ្រួសារក្រីក្រ** ដោយដកចេញនូវឧបសគ្គដែលបច្ចុប្បន្ននេះកំពុងបន្ថចបង្អាក់ផលិតភាព និងភាពទាញយកផលចំណេញរបស់កសិករខ្នាតតូចតាច ហើយទន្ទឹមនឹងនោះ ធ្វើការវិនិយោគលើអភិបាលកិច្ចសេដ្ឋកិច្ចស្អាតស្អំ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងមុខជំនាញ ដើម្បីធ្វើឱ្យមាននិរន្តរភាព និងភាពចំរុះសំរាប់ការងារ និងបង្កើតកាលានុវត្តភាពនៅក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម។ របាយការណ៍នេះទទូចស្នើរឱ្យប្រទេសកម្ពុជា ដែលមានផលិតភាពកសិកម្មក៏រិតទាបមែនទែន បើប្រៀបធៀបនឹងប្រទេសផ្សេងទៀតក្នុងតំបន់នេះ ធ្វើការអភិវឌ្ឍន៍ថែមទៀតនូវចលករកំណើនឱ្យរីកដុះដាលដល់តំបន់ជនបទ និងជួយជនក្រីក្រ អោយប្រសើរជាងមុន។

- **ពង្រីកវិនិយោគវិស័យសុខាភិបាល និងអប់រំ** ដោយផ្តោតការយកចិត្តទុកដាក់លើការពង្រឹងសមិទ្ធិផល ដែលធ្វើបានក្នុងការបង្កើនការចូលរៀននៅបឋមសិក្សា ទន្ទឹមនឹងនោះ ដោះស្រាយឧបសគ្គនៃការរៀនសូត្រនៅ

បឋមសិក្សាកំរិតខ្ពស់ និងការកែលំអគុណភាពការបង្រៀន កម្មវិធីអក្ខរកម្មសាកលសំរាប់មនុស្សពេញវ័យ ដើម្បីកែលំអមុខជំនាញ និងផលិតភាពសំរាប់ មនុស្សដែលសកម្មផ្នែកសេដ្ឋកិច្ចក្នុង ជំនាន់បច្ចុប្បន្ន ការកែលំអគុណភាព និងកាត់បន្ថយតំលៃចំណាយសេវាសុខាភិបាលសាធារណៈ និងការអភិវឌ្ឍកម្មវិធីពហុវិស័យ ដើម្បីដោះស្រាយបញ្ហាសុខាភិបាលសាធារណៈរ៉ាំរ៉ៃ ដូចជា កង្វះខាត អាហារូបត្ថម្ភ និងការស្លាប់របស់ម្តាយដ៏ធ្ងន់ធ្ងរ ក៏ដូចជាបញ្ចេញសកម្មភាពភ្លាមៗ ដើម្បីលើកកំពស់ការ ផ្លាស់ប្តូរឥរិយាបទសំរាប់ដោះស្រាយ បញ្ហាសុខភាពថ្មីៗ ដូចជា ការជក់បារីជាដើម ។

- **ភាពជាដៃគូសំរាប់ការកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធិភាពជាងមុនៈ** ការកែលំអប្រសិទ្ធិភាពរបស់ជំនួយសំរាប់ការកាត់បន្ថយភាពក្រីក្រ ទាមទារការរីកចំរើនលើការងារឈានមុខ ដូចជាកម្មសិទ្ធិ ការតំរែតំរង់ និងសុខដុមភាវូបនីយកម្ម ។ ផែនការអភិវឌ្ឍន៍ជាយុទ្ធសាស្ត្រថ្នាក់ជាតិ (NSDP) របស់រដ្ឋាភិបាលត្រូវបំរើជាក្របខណ្ឌការងារសំរាប់ម្ចាស់ជំនួយតំរែតំរង់ការគាំទ្រឆ្ពោះរបស់គេដល់គំរូវការអាទិភាពរបស់រដ្ឋាភិបាល ។ ម្ចាស់ជំនួយត្រូវបង្កើនសុខដុមភាវូបនីយកម្មចំពោះកិច្ចប្រតិបត្តិការងាររបស់ខ្លួនផ្ទាល់ ដើម្បីកាត់បន្ថយតំលៃចំណាយអន្តរកាលដែលរដ្ឋាភិបាលកំពុងប្រឈម ។ ទន្ទឹមនឹងនេះ ភាពជាដៃគូដ៏រឹងមាំជាងមុន ជាមួយរដ្ឋាភិបាល ម្ចាស់ជំនួយ និងសង្គមស៊ីវិលត្រូវផ្តល់មូលដ្ឋានសំរាប់ការត្រួតពិនិត្យ និងការវាយតំលៃលើការរីកចំរើនក្នុងការអនុវត្តន៍ និងលទ្ធផលនៃផែនការអភិវឌ្ឍន៍ជាយុទ្ធសាស្ត្រថ្នាក់ជាតិ (NSDP) ។

ក្លែរ ម៉ូរាន (Claire Moran) ប្រធានគ្រប់គ្រងប្រចាំប្រទេសកម្ពុជារបស់ក្រសួងអភិវឌ្ឍន៍អន្តរជាតិរបស់ចក្រភពអង់គ្លេស (DFID) បានចាត់ទុកសន្និសិទនេះជាជំហានទីមួយនៃការសន្ទនាទរចាដែលបញ្ចូលគំនិត ជាច្រើនស្តីពីគោលនយោបាយ ។ លោកមានប្រសាសន៍ថា *"សន្និសិទថ្ងៃនេះគឺជាឱកាសលើកទីមួយដែលមន្ត្រីសំរេចគោលនយោបាយសំខាន់ៗ សមាជិកសហគមន៍អភិវឌ្ឍន៍ និងសង្គមស៊ីវិល មានលទ្ធភាពមកជួបជុំគ្នា ដើម្បីពិភាក្សាគ្នាយ៉ាងស៊ីជំរៅពីបញ្ហាប្រឈមក្នុងការកាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជាសំរាប់ជាផលចំណេញរបស់មនុស្សជំនាន់បច្ចុប្បន្ននេះ និងក៏សំរាប់មនុស្សជំនាន់ក្រោយៗទៀតដែរ ។ មេរៀនទាំងឡាយដែលដកស្រង់ចេញពី បទពិសោធន៍នៅប្រទេសកម្ពុជានឹងក្លាយជាធាតុចូលដ៏សំខាន់បំផុតសំរាប់សន្និសិទអន្តរជាតិស្តីពីការលើកកំពស់កំណើនសេដ្ឋកិច្ច និងការបញ្ចប់ភាពក្រីក្រនៅទ្វីបអាស៊ី ដែលនឹងពិភាក្សាពីការផ្លាស់ប្តូរមុខមាត់នៃការអភិវឌ្ឍន៍នៅទ្វីបអាស៊ី ក្នុងទសវត្សក្រោយព្រមទាំងសំដៅឈានទៅដល់កិច្ចព្រមព្រៀងស្តីពីវិធីសាស្ត្រ ដែលប្រទេសនៅទ្វីបអាស៊ី ជាមួយនឹងទីភ្នាក់ងារអភិវឌ្ឍន៍ និងសហគមន៍អន្តរជាតិអាចធ្វើការរួមគ្នា ដើម្បីសំរេចគោលដៅការអភិវឌ្ឍន៍សហសវត្សដែលនៅសេសសល់"* ។

ចំពោះព័ត៌មានស្តីពីការវាយតំលៃភាពក្រីក្រនៅកម្ពុជា ឆ្នាំ ២00៦ សូមមើលវេបសាយរបស់យើងតាម អសយដ្ឋាន: www.worldbank.org/kh ។ កំរងចំលើយចំពោះសំនួរដែលនិយមលើកឡើងជាញឹកញាប់ (FAQs) ស្តីពីបន្ទាត់ភាពក្រីក្រ និងការវាស់ភាពក្រីក្រក៏មាននៅក្នុងវេបសាយនេះដែរ។

ចំពោះព័ត៌មានបន្ថែមស្តីពី **ទ្វីបអាស៊ីឆ្នាំ ២០១៥:ការលើកកំពស់កំណើនសេដ្ឋកិច្ច និងការបញ្ចប់ភាពក្រីក្រ** សូមមើលវេបសាយរបស់យើងតាមអសយដ្ឋាន: www.asia2015conference.org ។ ឯកសារសំរាប់ការពិភាក្សានៅសន្និសិទទាំងអស់នឹងត្រូវបានដាក់តាមវេបសាយនេះមុន ហើយវេបសាយនេះនឹងផ្តល់ឱកាសសំរាប់សាធារណជនបញ្ចេញយោបល់របស់ខ្លួនស្តីអំពីបញ្ហាអភិវឌ្ឍន៍អាស៊ី ។